# សេចក្តីថ្លែងការណ៍

## គណៈកម្មាធិការយុវជន នៃសហព័ន្ធខ្មែរកម្ពុជាក្រោម
## ថ្កោលទោសចំពោះការគំរាមកំហែងយុវជនខ្មែរក្រោម
## ដោយនគរបាលវៀតណាម និងអាជ្ញាធរមូលដ្ឋាន

...............

*"ជនជាតិដើមគ្រប់រូបមានសិទ្ធិប្រតិបត្តិ និងធ្វើឲ្យរស់ឡើងវិញនូវប្រពៃណី និង ទំនៀម ទម្លាប់ជាវប្បធម៌របស់ខ្លួន ។ សិទ្ធិនេះ រួមមានទាំងសិទ្ធិក្នុងការថែរក្សា ការពារ និង អភិវឌ្ឍន៍ អ្វីដែលបង្ហាញអំពីអត្តសញ្ញាណ វប្បធម៌របស់ខ្លួន ដែលមានពីអតីតកាល បច្ចុប្បន្ន និងអនាគត ដូចជា បុរាណវិទ្យា និងស្ថានីយប្រវត្តិសាស្ត្រ បុរាណវត្ថុ រចនាបថ្ម ពិធីបុណ្យ បច្ចេកវិទ្យា និង សិល្បៈ ទស្សនីយភាព និងការសម្តែងសិល្បៈ និង អក្សរសាស្ត្រ ។"* មាត្រាទី ១១ នៃ UNDRIP

ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៧

ដើម្បីឆ្លើយតបទៅនឹងការបំភិតបំភ័យនាពេលថ្មីៗ ដែលរដ្ឋាភិបាលវៀតណាមបានកោះហៅក្រុមយុវជនជនជាតិដើមខ្មែរក្រោម នៅភូមិមេរងថ្មី ស្រុកផ្ទោងដាច់ ខេត្តព្រះត្រពាំង ទៅសួរចម្លើយជាលើកទី ២ គណៈកម្មាធិការយុវជននៃសហព័ន្ធខ្មែរកម្ពុជាក្រោម (KKFYC) សូមថ្កោលទោសចំពោះការរំលោភទាំងស្រុងទៅលើសិទ្ធិខ្មែរក្រោមដោយរដ្ឋាភិបាលវៀតណាម ។

យើងខ្ញុំសុំស្នើឱ្យរដ្ឋាភិបាលវៀតណាមអនុវត្តនូវវិធានការសមស្រប ដើម្បីអប់រំ និងផ្សព្វផ្សាយនូវរដ្ឋធម្មនុញ្ញវៀតណាមដែលទាក់ទងទៅនឹងសិទ្ធិរបស់ជនជាតិដើម ដើម្បីឲ្យជនជាតិដើមអាចបញ្ជាក់ និងបង្ហាញនូវអត្តសញ្ញាណខ្លួនឯង និងការរក្សាអត្តសញ្ញាណ វប្បធម៌ដ៏ប្រពៃរបស់ពួកគេ ។

គួររំឭកផងដែរថា វៀតណាមមានកាតព្វកិច្ចអនុវត្តតាមសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP) ដើម្បីជួយការពារជនជាតិដើម វប្បធម៌ និងអត្តសញ្ញាណរបស់ពួកគេ ។ គួររំឭកឡើងដែរថា នៅក្នុងមហាសន្និបាត លើកទី ១៦ នៃវេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិ ស្តីបញ្ហាជនជាតិដើម (UNPFII) រយៈពេល ២ សប្តាហ៍ចាប់ពីថ្ងៃ ទី ២៤ ខែមេសា ដល់ ៥ ខែឧសភា ឆ្នាំ ២០១៧ ដែលមានវត្តមាន តំណាងប្រទេសវៀតណាមចូលរួមដែរនោះ ផ្តោតលើប្រធានបទ "ខួប ១០ ឆ្នាំ នៃការអនុម័ត នៃសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP) និងការអនុវត្តលើសេចក្តីប្រកាស នេះ" ។

ក្រៅពីចូលរួមប្រជុំ និងថ្លែងការណ៍នៅក្នុងវេទិកា UNPFII គណៈ កម្មាធិការយុវជននៃសហព័ន្ធខ្មែរកម្ពុជាក្រោម (KKFYC) ដែលជាអង្គការតស៊ូមតិអន្តរជាតិរបស់ យុវជនសម្រាប់លើកកម្ពស់សិទ្ធិជនជាតិដើម បានរចនាអាវយឺតដើម្បីលើកកម្ពស់សេចក្ដីប្រកាស ជាសកលរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) ស្របជាមួយនឹងគោល ដៅនៃមហាសន្និបាតលើកទី ១៦ នៃវេទិកា UNPFII និងស្របនឹងស្មារតីនៃសេចក្ដីប្រកាសជា សកលរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) ដែលប្រទេសវៀតណាម បានអនុម័តកាលពីឆ្នាំ ២០០៧ ។

ក្រុមយុវជនខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម មើលឃើញអាវយឺតមានលក្ខណៈលើកកម្ពស់នូវអត្តសញ្ញាណជនជាតិដើមរបស់ខ្លួន បានយកវាទីបោះពុម្ពដើម្បីចែកគ្នាពាក់ ។ ផ្ទុយទៅវិញ គំនិតផ្ដួចផ្ដើមគួរឲ្យកោតសរសើររបស់ក្រុមយុវជនជនជាតិដើមក្នុងការលើកកម្ពស់ និងផ្សព្វផ្សាយនូវសេចក្ដីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) ដែលរដ្ឋាភិបាលវៀតណាមមានកាតព្វកិច្ចត្រូវធ្វើដោយខ្លួនឯងនោះ រដ្ឋាភិបាលវៀតណាមបានតបមកវិញដោយជ្រើសរើសវិធីដាក់ពិន័យក្រុមយុវជនតាមរយៈកោះហៅទៅសួរចម្លើយ នៅការិយាល័យនគរបាលដើម្បីគំរាមកំហែង ។

គណៈកម្មាធិការយុវជននៃសហព័ន្ធខ្មែរកម្ពុជាក្រោម (KKFYC) ស្នើសុំឱ្យរដ្ឋាភិបាលវៀតណាម រកដំណោះស្រាយបញ្ហាបំភិទបំភ័យនៅក្នុងតំបន់មួយនេះ និងចាប់ផ្ដើមចូលរួមក្នុងការជួយលើកកម្ពស់ និងផ្សព្វផ្សាយនូវសេចក្ដីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) សម្រាប់ជនជាតិដើមទាំងអស់របស់ខ្លួន តាមរយៈការជួយបកប្រែ និងផ្សព្វផ្សាយសេចក្ដីប្រកាសនេះទៅជាភាសាកំណើតរបស់ពួកគេ ។

គណៈកម្មាធិការយុវជននៃសហព័ន្ធខ្មែរកម្ពុជាក្រោម នឹងបន្តតាមដាននូវស្ថានភាពនេះយ៉ាងយកចិត្តទុកដាក់ និងទទូចឲ្យមានការដោះស្រាយឲ្យបានទាន់ពេលវេលា តាមរយៈការគោរព និងការទទួលស្គាល់សិទ្ធិជនជាតិដើមរបស់រដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ នៅក្នុងប្រទេសវៀតណាម ៕

គណៈកម្មាធិការយុវជន នៃសហព័ន្ធខ្មែរកម្ពុជាក្រោម (KKFYC)

North America – Europe – Australia – Asia

ទាក់ទង៖ *kkfyc.group@gmail.com* ឬ *info@kkfyc.org*



CÔNG AN CẦU NGANG
CÔNG AN THẠNH HÒA SƠN

Số: 1 /GM

CỘNG HÒA XÃ HỘI CHỦ NGHĨA VIỆT NAM
Độc lập – Tự do – Hạnh phúc

*Thạnh Hòa Sơn, ngày 26 tháng 5 năm 2017*

**GIẤY MỜI**

*Kính mời:* Ông, bà: Kim Sang; Sinh năm: 1988
Địa chỉ thường trú: Ấp Lạc Sơn, Thạnh Hòa Sơn – Cầu Ngang – Trà Vinh.
Đúng 10 giờ 30 phút, ngày [illegible] tháng 5 năm 2017.
Đến tại: Công an xã Thạnh Hòa Sơn.
Gặp đồng chí: Sơn Thanh Bạch- Chức vụ: Đội trưởng đội an ninh, Công an Cầu Ngang.
Lý do: Hỏi thăm một số việc có liên quan.
Yêu cầu ông, bà đến đúng thời gian và địa điểm qui định, khi đi đem theo giấy mời.

TM.BCH CÔNG AN XÃ
PHÓ CÔNG AN XÃ

Vậy nhờ các đồng chí chuyển giấy mời số 1 của công an xã Thạnh Hòa Sơn cho đương sự. Yêu cầu đương sự ký nhận và gửi lại cho công an xã Thạnh Hòa Sơn./.

NGƯỜI NHẬN
(Ký, ghi họ tên)

លិខិតរបស់នគរបាលវៀតណាមស្រុកផ្នោដាច់ ខេត្តព្រះត្រពាំង ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៧
កោះហៅ លោក គឹម សាង នៅភូមិមេរងថ្មី ទៅសួរចម្លើយរឿងពាក់អាវយឺតខ្មែរក្រោម ។



ក្រុមយុវជនភូមិមេរងថ្មី ពាក់អាវយឺតខ្មែរក្រោម ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៧ ។



ក្រុមយុវជនភូមិមេរងថ្មី នាង សឺន ស្រីណែត និង ថាច់ ធី សា ពាក់អាវយឺតខ្មែរក្រោម
នៅស្រះគូ នាទីរួមខេត្តព្រះត្រពាំង ។



លោក តូ ហ្វាង ចឿង និងក្រុមរបស់ខ្លួននៅមុខការិយាល័យនគរបាលវៀតណាម
ដើម្បីរង់ចាំការសួរចម្លើយពីភ្នាក់ងារអាជ្ញាធរយួន ។